ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 30 / 04 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ny

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០១/១៨ កក្កដា ឆ្នាំ ២០០៧-អវតក/អជសដ
Case File/Dossier N° 001/18-07-2007-ECCC/TC

| | |
|---|---|
| ចំពោះមុខ | ចៅក្រម និល ណុន ជាប្រធាន |
| | ចៅក្រម Silvia CARTWRIGHT |
| | ចៅក្រម យ៉ា សុខន |
| | ចៅក្រម Jean-Marc LAVERGNE |
| | ចៅក្រម ធូ មណី |
| កាលបរិច្ឆេទ | ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៩ |
| ប្រភេទឯកសារ | សាធារណៈ |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 04 / MAY / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A.Ny

# ដីកាសម្រេចកំណត់កាលវិភាគសវនាការនៅតាម
# អង្គហេតុសម្រាប់ថ្ងៃទី ១៨ ខែឧសភា ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៩

**សហព្រះរាជអាជ្ញា**

ជា លាង
Robert PETIT

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

គង់ ពិសី
ហុង គីមសួន
យុង ផានិត

Pierre Olivier SUR
Alain WERNER
Brianne McGONIGLE
Annie DELAHAIE

**ជនជាប់ចោទ**

កាំង ហ្គេកអ៊ាវ ហៅ ឌុច

**មេធាវីជនជាប់ចោទ**

ការ សាវុត្ថ
François ROUX
MARIE-PAULE CANIZARES

អង្គជំនុំជម្រះសាលាដំបូង
TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE
E C C C • C E T C

គីម ម៉េងឃី
ម៉ុច សុវណ្ណារី
Silke STUDZINSKY
Martine JACQUIN

Philippe CANNONE
ទី ស្រីនណា
Elizabeth RABESANDRATANA
Karim KHAN

យើង **និល ណុន** ប្រធាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា។

**ក្រោយពីបានទទួល** សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ តាមសាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនិងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណីរបស់ **កាំង ហ្គេកអ៊ាវ** ហៅ ឌុច ដែលអង្គបុរេជំនុំជម្រះបានសម្រេច និងប្រកាសនៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០០៨ និងបញ្ចូលសេចក្តីសម្រេចនេះជាភាសាខ្មែរទៅក្នុងសំណុំរឿងនៅថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០០៨ ("សេចក្តីសម្រេច") ។

**បានឃើញ** ដីកាសម្រេចកំណត់កាលបរិច្ឆេទចាប់ផ្តើមសវនាការលើអង្គសេចក្តី និងថ្ងៃជំនុំជម្រះសម្រាប់រយៈពេលបីខែដំបូងចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ ២០០៩[1]។

**បានឃើញ** សេចក្តីណែនាំស្តីពីកម្មវិធីជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ ២០០៩[2]និង ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០០៩[3]។

**បានឃើញ** សេចក្តីសម្រេចលើសំណើសុំវិធានការការពារសាក្សី និងអ្នកជំនាញ និងសំណើរបស់ភាគី ស្តាប់ចម្លើយសាក្សី និងអ្នកជំនាញ (សង្ខេប) ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០០៩[4]។

**រំលឹកឡើងវិញថា** សវនាការលើអង្គសេចក្តីបានចាប់ផ្តើមកាលពីថ្ងៃទី ៣០ ខែមីនា ឆ្នាំ២០០៩។

**បានកត់សំគាល់ឃើញថា** សប្តាហ៍ទី ១ នៃខែ មិថុនា ឆ្នាំ ២០០៩ អង្គបុរេជំនុំជម្រះបានសម្រេចដាក់កម្មវិធីជំនុំជម្រះនៅសាលសវនាការធំនេះ។

**ដោយពិចារណាអំពី** ភាពចាំបាច់ក្នុងការជូនដំណឹងអោយបានគ្រប់គ្រាន់អំពីកាលបរិច្ឆេទសវនាការដល់ភាគីទាំងអស់ ក៏ដូចជាសាក្សី និងអ្នកជំនាញដែលត្រូវធ្វើសក្ខីកម្ម។

---

[1] មើលឯកសារ E15

[2] មើលឯកសារ E26

[3] មើលឯកសារ E48

[4] មើលឯកសារ E40



**ហេតុដូច្នេះ**

**សម្រេច** កំណត់កាលវិភាគសវនាការលើអង្គសេចក្តីសម្រាប់ពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ និង ពីថ្ងៃទី ៨ ដល់ថ្ងៃទី ២៥ មិថុនា ឆ្នាំ ២០០៩ ចំពោះអង្គហេតុមួយចំនួនដូចខាងក្រោម៖

- **ការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស ២១ (បន្ត) និងជម្លោះប្រដាប់អាវុធ៖** ចាប់ផ្តើមធ្វើពីថ្ងៃទី ១៨ ដល់ថ្ងៃទី ២១ ខែឧសភា ឆ្នាំ ២០០៩។ ក្នុងអំឡុងពេលនេះគឺមានការសួរសំណួរទៅអ្នកជំនាញ Craig Etcheson (KW-02) ទាក់ទងនឹងអង្គហេតុនៃការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស ២១។ បន្ទាប់មកមានការសួរសំណួរទៅជនជាប់ចោទ ទាក់ទងនឹងអង្គហេតុជម្លោះប្រដាប់អាវុធ។

- **ជម្លោះប្រដាប់អាវុធ (បន្ត) និង ប្រតិបត្តិការរបស់មន្ទីរស.២១ រួមបញ្ចូលទាំងជើងឯក៖** ចាប់ផ្តើមធ្វើពីថ្ងៃទី ២៥ ដល់ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០៩ និង ពីថ្ងៃទី ០៨ ដល់ថ្ងៃទី ២៥ ខែមិថុនា ឆ្នាំ ២០០៩។ ក្នុងអំឡុងពេលនេះមានការស្តាប់សក្ខីកម្មរបស់សាក្សី (KW-09),(KW-08) និងអ្នកជំនាញ Nayan Chanda (KW-26) ទាក់ទងនឹងអង្គហេតុជម្លោះប្រដាប់អាវុធ បន្ទាប់មកចាប់ផ្តើមសួរសំណួរទៅជនជាប់ចោទ និងស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី គឺ (D25/1), (D25/3), សាក្សី (KW-01) និងស្តាប់សក្ខីកម្មរបស់សាក្សី (CP1/6) ទាក់ទងនឹងអង្គហេតុប្រតិបត្តិការរបស់មន្ទីរ ស.២១ រួមបញ្ចូលទាំងជើងឯក។

**សម្រេច** មិនធ្វើសវនាការសប្តាហ៍ទី១ នៃខែ មិថុនា ឆ្នាំ ២០០៩។

អង្គជំនុំជម្រះសាលាដំបូងសូមរក្សាសិទ្ធិក្នុងការកែប្រែកាលវិភាគនេះក្នុងករណីចាំបាច់។
ដីកាកំណត់កាលវិភាគបន្តបន្ទាប់ទៀតនៃដំណើរការនីតិវិធី អង្គជំនុំជម្រះនឹងកំណត់នៅពេលសមស្រប។

ភ្នំពេញ ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C

**និល - ណុន**